# នាយកដ្ឋានគរបាលឡុងប៊ិច

## បណ្ដាញព័ត៌មានសហគមន៍

នាយកដ្ឋាននគរបាលឡុងប៊ិច (LBPD) បានបង្កើត បណ្ដាញទូរសព្ទបណ្ដោះអាសន្ន ដើម្បីស្រាយ ចម្ងល់ និង ក្ដីបារម្ភនានាចំពោះ សកម្មភាពនគរបាល ពាក់ព័ន្ធនឹង ទិដ្ឋភាពដែលគេយល់ថាជាការអនុវត្តច្បាប់អន្តោប្រវេសន៍ ។

LBPD ទទួលខុសត្រូវ លើការរក្សាសុវត្ថិភាព ជូនសមាជិកសហគមន៍ និងភ្ញៀវ របស់យើង តាមរយៈការអនុវត្ត ច្បាប់សុវត្ថិភាពសាធារណៈ មិនមែន ច្បាប់អន្តោប្រវេសន៍សហព័ន្ធនោះទេ ។ LBPD ធ្វើប្រតិបត្តិការអនុវត្តច្បាប់ព្រហ្មទណ្ឌ ជាប្រចាំ ក្នុង កិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយ សកម្មភាពឧក្រិដ្ឋ នៅក្នុងសហគមន៍ របស់យើង ។

ប្រតិបត្តិការទាំងនេះ គ្មានទំនាក់ទំនង ជាមួយ ការអនុវត្តច្បាប់អន្តោប្រវេសន៍ស៊ីវិល នោះទេ ។

ប្រសិនបើលោកអ្នកមានចម្ងល់ណាមួយ ពាក់ព័ន្ធនឹង កិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់ របស់ LBPD សូមទំនាក់ទំនងមកយើងខ្ញុំ តាមរយៈលេខ

**(562) 570-7238**

បណ្ដាញព័ត៌មាននេះ មានផ្ដល់ជូនជា ភាសាអង់គ្លេស ភាសាអេស្ប៉ាញ ភាសាខ្មែរ និង ភាសាតាហ្គាឡុក ។

សូមដាក់ ឈ្មោះពេញ របស់លោកអ្នក សារលម្អិត ពាក់ព័ន្ធនឹង ចម្ងល់ ឬ ក្ដីបារម្ភ របស់លោកអ្នក ព្រមទាំង លេខទូរសព្ទ សម្រាប់គេហៅទៅវិញ ឬ សារអេឡិចត្រូនិក របស់លោកអ្នក ។

តំណាង មកពី LBPD នឹងហៅទូរសព្ទ ទៅរកលោកអ្នកវិញ នៅថ្ងៃធ្វើការ បន្ទាប់ទៀត ។

**បណ្ដាញនេះ មិនមែនសម្រាប់ រាយការណ៍ អំពីសកម្មភាព របស់ ICE នៅឡុងប៊ិច នោះទេ ។**

សម្រាប់ព័ត៌មានពាក់ព័ន្ធនឹង ការអនុវត្តច្បាប់អន្តោប្រវេសន៍ស៊ីវិល សូមទំនាក់ទំនងទៅ នាយកដ្ឋានអន្តោប្រវេសន៍និង ការិយាល័យទំនាក់ទំនងសហគមន៍ អនុវត្តច្បាប់ និងគយ តាមរយៈលេខ (562) 624-4088 ឬ ចូលទៅគេហទំព័រ របស់ពួកគេ នៅ www.ice.gov.

ដើម្បីបានព័ត៌មានបន្ថែមទៀត អំពី LBPD និង ដើម្បីពិនិត្យមើល ដីកាពិសេស ពាក់ព័ន្ធនឹង ការអនុវត្តច្បាប់អន្តោប្រវេសន៍សហព័ន្ធ សូមចូលមើលគេហទំព័រ របស់យើងខ្ញុំ នៅ ៖

http://www.longbeach.gov/police/about-the-lbpd/policies-and-procedures/